Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 5/1 (October 2004): 137–47



Brian MAHER

# Meet Molly Yos



*Molly YOS*

Molly Yos was born in Prey Veng province in 1960. She was the ninth of twelve children, only two of whom were boys. Her father, an official in the Ministry of Agriculture, supervised three provinces.

The family relocated to Phnom Penh in 1967 upon his promotion to Supervisor of Provincial Agriculture in Cambodia. Molly enrolled in Phnom Penh schools where she made friends with a girl named Young Setha—whom they called "Eang"—from Arey Ksach, the village directly across the river from the Royal Palace. Eang and Molly, both young teenagers in 1973, heard about a free English class. Phnom Penh during the sixties and early seventies was the hub of Southeast Asia and in touch with the pulse of both the region and the world. Molly and Eang did not want to be Cambodian teenagers who would

be referred to as "frogs in wells" or *boun cheroong* (square), so they were very interested in studying English. The classes were offered at the OMF Youth Center near Olympic Stadium. Molly and Eang found the place and enrolled to study English in their spare time. From the posted schedule they could choose their study topic from teachers Don Cormack, Alice Compain, Ruth Patterson, Rose Ellen Chancey, Andrew Way and Andrew Butler. Mr. Triev Sary was the Cambodian in charge. Both Eang and Molly first studied English from the gospels with Ruth Patterson. Then, when Rose Ellen Chancey came later, they studied English from the book of Genesis. They both bought English and Khmer Bibles to ensure they understood clearly.

Meanwhile, while Molly was studying her English, Molly's older brother Antipo had come to faith in Christ—the only Christian in the family. Molly was not much interested at the time, but sure took notice when her uncle beat him up after he preached the gospel to the family. As Molly was learning English from the Bible, Antipo was leading the youth group in the Bethany church.

Molly found the book of Genesis interesting and relevant because it answered many life questions about which she had wondered since childhood. The Buddhist religion posits neither a creation epic nor a creator God. Molly found the concept of a God who created her and knew her before she was born very comforting. As Molly studied Genesis, she gradually began to believe in this creator God and his son Jesus, and sometime in early 1974 gave her life to Christ. She began to attend Bethany church, led by Chhirc Taing (an officer in the army of Lon Nol's Republic and the older brother of Rev. Taing Vek Houng of Campus Crusade) and Mien Tien Voan (at that time Country Director of World Vision). Both Chhirc and his cousin Voan were later most likely martyred.[1]

Molly continued her study of English and the Khmer Bible at the Youth Center with Triev Sary on weekdays, and faithfully attended Bethany church on Sundays. During 1974, Molly began to help out at

---

[1]Helen Penfold mentions in *Remember Cambodia* that witnesses saw them clubbed to death by men clad in black shortly after the Khmer Rouge invaded in the city of Neak Loung.

the Youth Center, organizing the place and learning how to be a Bible study cell group leader. On Sundays after church, Molly, Rose Ellen Chancey, and her friends from church went out to share the gospel and hand out gospel tracts in the Tumnop Tek area of Phnom Penh, on the southeast rim of the city. Molly remembers selling tracts and Christian literature at the Olympic stadium when Dr. Stan Mooneyham preached in a large crusade.

Molly brought her younger sisters Sokun and Sotheavy to church with her, but it wasn't so easy convincing her parents to let them tag along. The fact that Sokun and Sotheary had become sponsor children of World Vision helped ease the concerns of her Buddhist parents who knew World Vision was a Christian organization. Through Molly's bringing them to church, both Sokun and Sotheavy became Christians and learned to work with the children in the church. Their parents even began to transport them back and forth from church activities. Molly's younger sister Sokun grew up to become a schoolteacher in the eighties, and worked for FEBC radio in the nineties. She currently works for World Vision Cambodia as a community development worker and has a great Christian witness.

In late 1974, Antipo's sharing his faith with Molly's two older sisters, Yos Im Sithan and Yos Sangkany, began to show some fruit. As Khmer Rouge artillery began to pound the city, these two older sisters gave their lives to Christ.

Treiv Sary, the director and manager of the Youth Center, realized that though he had evangelized and discipled these young people, other churches were using their gifts but not appreciating what he had done for them. In addition, churches like Bethany and Bethlehem were already overcrowded as more and more refugees daily arrived in Phnom Penh. So he decided to organize church services at the Youth Center on Sundays. Molly and Antipo stayed at Bethany and helped with smaller churches like Noah's Ark Church, an abandoned house boat stuck on the western bank of the Mekong. Noah's Ark was owned by a new believer from Bethlehem church, and Takmau Bible College students preached and ran the services there.

The Khmer Rouge were getting close, and there was fighting on the outskirts of the city. Eang, whose village was directly affected

by the fighting between Lon Nol's troops[2] and the Khmer Rouge, fled to the city and her family bought a house near the Olympic Market. Eang and Molly did everything together after that. Antipo, Sithan and Sangkany sold vegetables at Dam Tkeov market near the Tumnup Tek area. Sometime during 1974, Molly joined in a large baptism hosted by the Takmau Bible College. She remembers being encouraged to pray for the salvation of her parents by her youth pastor, Mr. Ngeth Samawn (Setha).

When Christmas rolled around, they celebrated the holiday with Rose Ellen and Alice at their home, together with other churches around Phnom Penh. All the expatriate missionaries in House #72 were packing their bags to leave, since it appeared to be only a matter of time before the Khmer Rouge would overrun the city. Molly's missionary friends warned her to not allow the Khmer Rouge to catch her with English books or a Khmer Bible.

On April 17, 1975, the Khmer Rouge entered Phnom Penh. They immediately began to execute Lon Nol's soldiers and others who had been a part of his government. Many soldiers buried their uniforms and joined the enforced mass exodus of the citizenry. Phnom Penh residents who were evacuated to the provinces came to be known as "new people." Many of these former city dwellers were to be systematically starved or worked to death. Others were simply taken away, never to be seen again.

In this mass exodus of over two million people, Molly and her family headed toward their home village in Prey Veng. They crossed the Mekong at Neak Loung, and made it to the town of Kompong Trabaek. Further into the countryside, they built a little house of bamboo and palm fronds. After arriving in Prey Veng province, most of the family contracted malaria. During this time of sickness, Molly's parents asked her to lead them to Christ. Molly and her mother were the sickest members of the family, and were taken to a rudimentary Khmer Rouge health clinic. The clinic had no medicine, and some patients were taken away to be killed.

---

[2]FANK—Forces Army National Kampuchea, the troops of Lon Nol's Republic.

After a few months Molly recovered, but her mother deteriorated. Those running the clinic were about to send Molly's mother home to die when she slipped into a three-day coma. In her coma she saw hairy demons chasing her, and soon became exhausted trying to flee from them. Two women came alongside her, each grabbing an arm, lifting it up, and supporting her. They encouraged her to keep going. In the distance loomed a white church. The two women took her past the white church and told her that it was a religious temple. She saw another church, this one was blood red and situated on the far side of a big ocean. The demons continued to chase her. They swam, but she was able to walk across on the water. As she arrived on the shore and set her foot on the steps leading into the church, the demons caught up to her. At that point, she yelled out, "Jesus, help me!" She saw Jesus coming out of the church saying; "I am Jesus Christ and this is Judgment Day." Upon hearing this, the demons fled. Molly's mother—in the real world—began moving her toe—a sign that she was still alive.

Soon after she returned from the clinic in good health. The family began to secretly read the Bible, but soon the situation became more repressive and they buried the Bible for fear of death from the Khmer Rouge. Even so, Molly's mother's faith began to blossom. But tests also came: Sotheary, the youngest in the family, suffered without medical care from dengue fever for seven days, and then died.

Molly was forced to plant rice and build paddy dikes in return for one bowl of watery gruel with a few rice kernels in the bottom. Seeing a dog run by made her mouth water as she thought about roasted dog meat. Because of lack of food and intense labor, Molly became ill. She had constant diarrhea, and quickly became dehydrated and malnourished. The authorities sent her to rest at another rudimentary clinic.

The Khmer Rouge were getting ready to conduct a mass marriage in Molly's village. Her mother insisted that Molly return from clinic and take part in this ceremony, thinking that if Molly married a villager, she might end up living close by. Molly was not thrilled with this idea at first, but eventually went along with her mother's wishes

and married Pot Sopharong in a group marriage ceremony in 1978. Her sister Yos Im Sithan was married in the same ceremony. .

. Ten days later, the Khmer Rouge forced the married couples to relocate to Pursat province in northwest Cambodia. Her mother, father, and sister decided to go too, and walked west all the way to Neak Luong. From there they were shipped north by truck to Phnom Penh, which was devoid of people. From Phnom Penh they took the train north to Pursat. During those difficult times under the Khmer Rouge, Molly's husband shared what food he had with her, and he carried her things when they were forced to move. She had a bad infection in her arm, and she is convinced that because of his help she remained alive and was able to survive the arduous journey

Antipo had been missing since they left Phnom Penh, as he was visiting his girlfriend when the Khmer Rouge entered the city. He had been relocated to Battambang, Cambodia's second largest urban center in the northwest, close to the border of Thailand. Molly remembers him recounting that three times the Khmer Rouge rounded him up for execution, but all three times the trucks were so filled that not even one more emaciated person could fit on the truck. After his third reprieve, Antipo fled to Thailand and joined the former Prime Minister of the sixties, Son Sanne, and the KPNLF (Free Khmer) to fight against the Khmer Rouge. He was the accountant for the KPNLF, until accused of pilfering funds and sent to the front where he was badly shot. He went to a Thai hospital to recover, then lived with a Thai family until he recuperated.

1978 was an extremely difficult year for Cambodians in terms of food security, as the Khmer Rouge exported a large percentage of rice to China and stored the rest in their mountain hideouts. Devastating floods also hit Cambodia's rice bowl that year, wiping out any rice that poor starving Cambodians might depend on.

On Christmas Day, 1978, Vietnamese forces entered Cambodia after the Khmer Rouge relentlessly attacked and massacred Vietnamese citizens living inside the Cambodian-Vietnamese border, especially in the Kampuchea Krom and Mekong Delta area. On January 7, 1979, Vietnamese troops victoriously entered Phnom Penh. From there they pushed the Khmer Rouge leadership into the

mountainous northwest along the Thai border, where they were safe in their Thai-protected border enclaves.

Vietnamese troops allowed Molly and her family to leave Pursat, but did not permit them to return to Phnom Penh. Instead they went to Prey Veng. They fortunately were able to go back to the family plot in their home village of the sixties, rather than the village where they lived during the Pol Pot regime. It was rice harvest time, but the fleeing, wounded, black-clad Khmer Rouge had torched the rice fields, poisoned wells, and destroyed roads and houses. Molly's family had little food, so were forced to beg from their neighbors. They worked out an arrangement under which Molly and her family worked long hours plowing and planting in the neighbor's rice fields, exchanging labor for rice to eat. For that whole year, they had little means for procuring food of any type. Six hundred thousand people died of starvation during the first year of the Vietnamese occupation. Under the Vietnamese K-5 program, any Cambodians suspected of not supporting the regime were sent to clear jungle and fortify areas against the DK[3] in mountainous regions of Battambang.

The new government—the Peoples' Republic of Kampuchea, led by Heng Samrin, Chea Sim, and Hun Sen (all having ties with the Vietnamese)—recalled Molly's father to his government agricultural position and to further studies. At the end of one year on the Prey Veng homestead they moved back to Phnom Penh, and Molly went to work for the Ministry of Agriculture. Her husband also went to work there, and made a lot of new friends who had a bad influence on him. He was soon squandering what little salary he earned on drinking and gambling. When their first child was born in 1981, he no longer took much interest in Molly or helping her raise the family. Molly tried her best to get him to change his ways but she could not, and resigned herself to care for her child without his help, depending on her mother and sisters for food and money to help pay the bills.

Sometime in the very early eighties Molly met up again with Eang. Eang was secretly worshipping at the underground Takmau church and invited Molly to join them, but Molly's father said "No"

---

[3]DK: Democratic Kampuchea, Khmer Krahom, or Khmer Rouge.

because it was too dangerous. Molly had enjoyed little conscious spiritual activity since 1975. But in 1988 her father began to succumb to the effects of high blood pressure, so Molly went to find Eang. Eang brought Molly to her pastor, Seing Ang, who prayed over Molly's father and anointed him with oil. He died months after that and went to be with the Lord.

Since the whole family wanted to bury their father according to Christian tradition rather than cremating him as in the Buddhist tradition, they called Pastor Seing Ang back to lead the funeral. That was in July of 1988. They didn't even bother to get permission from the government but went ahead with the funeral. There was a huge turnout. All the government friends of her father came, as well as friends of Molly, Sithan, and the other children. The underground church came out at this funeral for the first time. They all sang and worshipped God. Many pre-1975 Christians, many of whom came to Christ at the Stan Mooneyham Crusades, came out for the funeral. Attending were Pastor Im Chhorn, Pastor Muth Bunthy, Miss Yorng Setha, Mrs. Ngeth Sambo, Miss Srey Heim, and Heim's mother, as well as Molly and her family. Molly remembers the funeral procession being miles long.

An unexpected problem arose: "Where do we bury him?" A Vietnamese-Cambodian Christian, Paul Ba, helped contact the Catholic church, which allowed Molly's father to be buried in a Catholic Vietnamese cemetery in Kean Svay District, just over the river toward the southeast, off of Route One.

Through the funeral, Molly became aware of other believers who were meeting in secret locations around town. In 1989 it was estimated that there were no more than two hundred Christians in Phnom Penh.

Molly recounts, "One day not too long after the first public baptism in the Kantoeut River, west of Phnom Penh (done surreptitiously with about fifty believers), I saw my sister Sithan hold a paper in her hand. She was asking other key Christians to sign it. She had about ten signatures on what apparently was a petition of some sort. My sister was working at that time in the Ministry of Education, and was respected by her colleagues. She submitted that petition to an important man in the government who sent it through the system; it eventually

arrived on the desk of the Minister of Cults and Religion." Fortunately, Sithan had a longtime friend who turned out to be the wife of this minister and was able to arrange an audience with him. Molly and her sister met with the man and implored him: "Under this regime we have no right to worship in the tradition of our faith, no place to bury our dead according to our tradition, no rights at all. This isn't right. What can you do for us?"

The three Yos sisters, Molly, Sithan, and Sokun, bicycled to the minister's house every afternoon for more than three months. He wanted to learn more about Christianity in order to make an informed presentation of their case to the government. Each afternoon they sang hymns, worshipped, taught from the Bible, and listened to worship songs on cassette. The minister even borrowed cassettes to listen in his car going back and forth from work. He asked many questions, which they answered.

During this time, Molly had dreamed that she and her family were running around the nearby Olympic Stadium, shouting joyfully to everyone in hearing distance: "Bravo Jesus, Bravo!" She felt God was telling her that they would be given a decisive victory that would break Satan's strong grip over her beloved land.

Meanwhile, Molly's father's funeral had spurred local Christian leaders to form a provisional church committee comprised of ten members (four of them women), and headed by Pastor Siang.[4] Molly's sister Yos Im Sithan was on that council. It was June of 1989, and Christians were hoping for changes in the new state constitution showing more tolerance toward Christianity. That June, the Council of Ministers permitted Christians to express their faith in worship, but did not permit evangelism.

While Yos Sithan, Molly, Sokun, and others continued to meet with the minister, the Cambodian church was invited to attend the Lausanne II World Conference in the Philippines. They could not attend, but did send a report about their situation. This mobilized those

---

[4]Don Cormack, *Killing Fields Living Fields: An Unfinished Portrait of the Cambodian Church—the Church that Would Not Die* (Crowborough, East Sussex: OMF, 1997), 391.

attending to pray fervently for official freedom of religion for the church in Cambodia.

On the last day the sisters met with the minister, he asked them if Christians got involved in politics. Molly explained from Romans 13 that God ordains leaders of a country and Christians are encouraged to submit to and pray for their leaders. She reassured him that Christians in Cambodia only wanted freedom to worship, not stir up unrest in an already unstable country. The next day he called them back, quite shaken up about something one of his superiors might have said. He asked them again to explain to him very clearly about the political part. Molly explained once again that Christianity would not intentionally cause problems for the government; they only wanted freedom to follow their religious tradition legally. The minister went back to make his second appeal to the government. The very next Sunday, April 7, 1990, ten months after Lausanne, during a worship service in Molly's house, the Cambodian Government formally announced its recognition of the Christian Church. The next week, in the presence of government representatives, 1,500 Christians—Catholic and Protestant, Cambodian and Vietnamese—celebrated their new freedom together in Phnom Penh's largest auditorium.

The government remained wary of Christians; Molly and Sithan were among those followed by spies. Since Sithan was the primary mover and shaker in obtaining freedom for Christianity, the government wanted her to keep a tight lid on things to ensure that the church did not abuse its newfound freedom. Tight restraint was impossible after Christianity began to grow rapidly and missionaries and denominations arrived from all over the world. It was a Texas-based evangelist Mike Evans who almost lost freedom for Christianity in November 1994 in his ill-conceived Olympic Stadium crusade. Many missionaries in Cambodia had advised him against coming, but he came anyway because he thought God told him to. The crusade was a disaster. The advertising promised that everyone who attended would be healed, and that did not happen. The church experienced blatant persecution for the first time since it had gained freedom.

Yos Molly, Yos Im Sithan, Yos Sokun, Young Setha (Eang) and Pastor Seang Ang played critical roles in obtaining freedom for

Christianity under Hun Sen's Cambodia. That freedom has been enjoyed by the church, Christian organizations, Christian NGOs, missionaries, and the Cambodian people to this day.

In October 1991, as Molly was applying to World Vision Cambodia, her husband continued to gamble. Molly's application was accepted, so she bore the burden of her husband's gambling and supported her three children with her own salary. On occasion, her husband would attempt to change, but such changes were short lived. He sometimes didn't come home at night, and even gambled away a motorbike or two that Molly had bought with her earnings. At World Vision she began as a receptionist and inventory clerk, but was soon promoted to assist in the Operations Support Unit, then Staff Development and Spiritual Nurture, two different entities under Human Resources. Under the Spiritual Nurture Department she helped create the World Vision Cambodia Holistic Witness Policy Paper, organized pastor fellowships, translated World Vision's core values into Khmer, led staff Bible studies, coordinated Friday chapel and Tuesday Bible forum, arranged retreats, and was responsible for the orientation of new staff. In February 1998 she was transferred to the Kompong Thom Operation. Kompong Thom is a three-hour drive north of Phnom Penh. In Kompong Thom, Molly led the Spiritual Nurture and Leadership and Staff Development programs, really two full-time jobs. One year later Molly was promoted to Operations Manager. In February 2002, for the sake of her family, she has returned to Phnom Penh to take a less demanding position as an Area Development Program capacity builder. Molly's husband did recently leave her, and she now continues to look after three children, a boy and two girls.

សំណុំឱកឃ្មុំ ៥/១ (តុលា ២០០៤): ១៤៨-៦៤



លោក ប្រាយអិន ម៉ាហ៊ើ

# ជួបជាមួយលោកស្រី យស់ មូល្លី



លោកស្រី យស់ មូល្លី

យស់ មូល្លី កើតក្នុងឆ្នាំ ១៩៦០ នៅខេត្តព្រៃវែង ។ អ្នកស្រីជាកូន ទី៩ នៅក្នុងគ្រួសារដែលមានកូន១២នាក់ ហើយមានតែកូនប្រុស ២នាក់ ទេ នៅក្នុងគ្រួសារនោះ ។ ឪពុករបស់អ្នកស្រីជាមន្ត្រីផ្នែកក្រសួងកសិកម្ម ដែលទទួលខុសត្រូវមើលបីខេត្ត ។

គ្រួសារគាត់បានមករស់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៦៧ គឺនៅពេលដែលឪពុកគាត់ត្រូវបានគេចាត់តាំងឲ្យធ្វើជាទីប្រឹក្សាកសិកម្មថ្នាក់ខេត្តនៅក្នុងប្រទេសកម្ពុជា ។ មូល្លី បានចូលរៀនសាលានៅភ្នំពេញ នៅពេលនោះឯងដែលអ្នកស្រីបានបង្កើតមិត្តភាពជាមួយនារីម្នាក់ឈ្មោះ យ៉ង់ ស៊ីថា ដែលគេតែងតែហៅថា" អៀង" មកពីអរិយក្សត្រគឺជាភូមិមួយនៅត្រើយម្ខាងទន្លេទល់មុខព្រះបរមរាជវាំង ។ អៀង និង មូល្លី គឺនៅជា យុវជននៅឡើយ នៅក្នុងឆ្នាំ ១៩៧៣

ពេលមួយពួកគេបានឮដំណឹងពីការបង្រៀនអង់គ្លេសដោយឥតយកលុយ ។ កាលពីកំលុងឆ្នាំ១៩៦០និងដើមឆ្នាំ ១៩៧០ ទីក្រុងភ្នំពេញ គឺជាចំណុចកណ្ដាលនៃអាស៊ីអាគ្នេយ៍ដែលមានសន្ទុះទាំងក្នុងតំបន់ និងក្នុងពិភពលោក ។ មូល្លី និង អៀង មិនចង់ក្លាយជាយុវវ័យកម្ពុជាដែលគេតែងហៅថា " កង្កែបក្នុង អណ្ដូង ទេ " ឬ មនុស្សបួនជ្រុងនោះទេដូច្នេះពួកគេទាំងពីរមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការរៀនភាសាអង់គ្លេស ។ ផ្លាក់ទាំងអស់បើកឡើងនៅឯមជ្ឈមណ្ឌលយុវជន OMF ជិតស្ពាតអូឡាំពិច ។ មូល្លី និង អៀង បានរកឃើញ ហើយចុះឈ្មោះចូលរៀនអង់គ្លេសក្នុងម៉ោងទំនេររបស់ពួកគេ ។ តាមរយៈកាលវិភាគដែលបានបិទ ពួកគេអាចជ្រើសរើសមុខវិជ្ជាដែលត្រូវរៀនជាមួយលោកគ្រូ ដន ខូម៉ាក អាលីសកុំបុាំង រូថប៉ាត័រសាន់ រូសអេឡៃន អែនស៊ី អែនទ្រូវ៉េ និង អែនទ្រូបាត់ល័រ ។ លោក ទ្រាវសានី គឺអ្នកទទួលខុសត្រូវជនជាតិខ្មែរ ។ អៀង និង មូល្លី ទាំងពីរនាក់រៀនភាសាអង់គ្លេសតាមដំណឹងល្អទាំងបួនជាមួយរូថបាត័រសាន់ ។ បន្ទាប់មក រូស អេឡៃនអែនស៊ីបានមកតាមក្រោយ ពួកគេសិក្សាភាសាអង់គ្លេសតាមសៀវភៅលោកុប្បត្តិ ។ ពួកគេទិញព្រះគម្ពីរខ្មែរ និង ភាសាអង់គ្លេសមកដើម្បីបញ្ជាក់ឲ្យដឹងថាពួកគេពិតជាយល់បានច្បាស់ល្អ ។

ក្នុងខណៈពេលដែលអ្នកស្រីមូល្លី កំពុងរៀនភាសាអង់គ្លេស បងប្រុសរបស់អ្នកស្រី មូល្លី ឈ្មោះ អាន់ទីប៉ូ បានជឿលើព្រះយេស៊ូគ្រីស្ទ គឺមានតែគាត់តែម្នាក់ឯងគត់ដែលជាគ្រីស្ទាន នៅក្នុងគ្រួសាររបស់គាត់ ។ អ្នកស្រីមូល្លីមិនទាន់មានការចាប់អារម្មណ៍ចំពោះរឿងព្រះនៅពេលនោះទេ ប៉ុន្តែអ្នកស្រីមានការកត់សំគាល់នៅពេលដែលឪពុកធំរបស់គាត់បានវាយបងប្រុសគាត់ គឺនៅពេលដែលគាត់ផ្សាយដំណឹងល្អដល់គ្រួសារគាត់ ។ នៅពេលដែលអ្នកស្រី មូល្លី កំពុងរៀនភាសាអង់គ្លេសពីព្រះគម្ពីរ ចំណែកលោក អាន់ទីប៉ូពេលនោះ គឺជាអ្នកដឹកនាំយុវជននៅក្រុមជំនុំបេថានី ។

ម៉ូលីយល់ឃើញថាក័ណ្ឌគម្ពីរលោកុប្បត្តិមានការចាប់អារម្មណ៍ ហើយសមទៅនឹងហេតុការណ៍ ពីព្រោះវាបានឆ្លើយនូវសំណួរជាច្រើន អំពីជីវិតដែលអ្នកស្រីធ្លាប់ឆ្ងល់តាំងពីអ្នកស្រីនៅក្មេង ។ សាសនាព្រះពុទ្ធ មិនបាននិយាយអំពីការបង្កបង្កើតពិភពលោក ឬ ព្រះអាទិករឡើយ ។ មូល្លី បានរកឃើញពីការយល់ដឹងអំពីព្រះដែលបង្កើតអ្នកស្រីហើយស្គាល់ អ្នកស្រីតាំងពីអ្នកស្រីមិនទាន់កើត ។ នៅពេលដែលអ្នកស្រីរៀននៅក្នុង ព្រះគម្ពីរលោកុប្បត្តិ អ្នកស្រី ចាប់ផ្តើមជឿទៅលើព្រះដែលបង្កបង្កើត និង ព្រះរាជបុត្រាព្រះយេស៊ូគ្រីស្ទ ហើយ ប្រហែលជានៅក្នុងឆ្នាំ ១៩៧៤ អ្នកស្រី បានថ្វាយជីវិតនាងទៅព្រះគ្រីស្ទ ។ អ្នកស្រីបានចាប់ផ្តើមចូលរួមថ្វាយបង្គំ នៅព្រះវិហារបេថានី ដែលដឹកនាំដោយ លោកគ្រូ តាំង ឈៀក ( ដែលជា មន្ត្រីនៅក្នុងនាយទាហានសាធារណរដ្ឋ លន់ ណុល ហើយជាបងប្រុស លោកគ្រូ តាំងវេកហួង នៃអង្គការនិស្សិត និង ប្រជាជនថ្វាយព្រះគ្រីស្ទ ) និង លោក មៀន ផាន់វ៉ន ( ដែលនៅពេលនោះជានាយកប្រចាំប្រទេសរបស់អង្គការ ទស្សនៈពិភពលោក ) ។ ទាំងលោកគ្រូ ឈៀក និង លោក វ៉ន ក្រោយមកត្រូវ បាន សំលាប់ ដោយព្រោះតែជំនឿរបស់ខ្លួន [១] ។

អ្នកស្រីមូល្លី នៅបន្តរៀនភាសាអង់គ្លេស និង ព្រះគម្ពីរជាភាសាខ្មែរ នៅឯមជ្ឈមណ្ឌលយុវជន ជាមួយ ទ្រាវ សារី ក្នុងចុងសប្តាហ៍ ហើយចូលរួម ថ្វាយបង្គំយ៉ាងស្មោះត្រង់ នៅថ្ងៃអាទិត្យក្នុងព្រះវិហារបេថានី ។ នៅក្នុងឆ្នាំ ១៩៧៤ អ្នកស្រីមូល្លី បានចាប់ផ្តើមជួយការងារនៅក្នុងមជ្ឈមណ្ឌលយុវជនខាងផ្នែក រៀបចំកន្លែង និងជួយក្នុងការរៀនឲ្យទៅជាអ្នកដឹកនាំបង្រៀនគម្ពីរក្នុងក្រុមតូច ។ បន្ទាប់ពីទៅព្រះវិហារនៅថ្ងៃអាទិត្យរួចមក អ្នកស្រីមូល្លី រ៉ូស អេឡែនឆេនស៊ី

[១] ហេឡិន ផិនហ្គូល បានលើកឡើងមកនិយាយនៅក្នុងសៀវភៅ ឈ្មោះ *Remember Cambodia* ដែលបានឃើញពួកគេត្រូវពួកទាហានខ្មែរ ក្រហមសម្លាប់ ពេលដែលពួកទាហានអាវខ្មៅនេះលុកលុយនៅក្នុងទី ក្រុងអ្នកលឿង ។

និង មិត្តសម្លាញ់របស់គាត់ដែលនៅក្នុងក្រុមជំនុំជាមួយគ្នាបាននាំគ្នាចេញទៅផ្សាយដំណឹងល្អ និង ចែកខិត្តប័ណ្ណនៅក្នុងតំបន់ទំនប់ទឹកនៃទីក្រុងភ្នំពេញដែលនៅ ខាងភាគអាគ្នេយ៍នៃទីក្រុង ។ អ្នកស្រីមូលី នឹងចាំបានចំពោះការលក់ខិត្តប័ណ្ណនៅក្នុងពហុកីឡាដ្ឋានអូឡាំពិក នៅពេលដែលលោក បណ្ឌិត ស្ទែន ម៉ូនីហាំ អធិប្បាយក្នុងយុទ្ធនាការផ្សាយដំណឹងល្អយ៉ាងធំមួយនោះ ។

អ្នកស្រីមូលី បាននាំប្អូនស្រីរបស់គាត់ឈ្មោះសុគន្ធ និង សុធារី ទៅព្រះវិហារជាមួយគាត់ ប៉ុន្តែមិនមែនជាការងាយស្រួលទេក្នុងការដែលធ្វើឲ្យឪពុកម្តាយរបស់គាត់យល់ ហើយព្រមអនុញ្ញាតឲ្យគាត់នាំគេទៅព្រះវិហារជាមួយគាត់នោះឡើយ ។ ហេតុការណ៍ដែលធ្វើឲ្យឪពុកម្តាយរបស់គាត់ដែលជាអ្នកជឿព្រះពុទ្ធសាសនានោះ បានធូរស្រាលពីការព្រួយបារម្ភគឺនៅពេលដែល សុគន្ធ និងសុធារីបានទទួយការគាំទ្រពីកម្មវិធីជួយគាំទ្រកុមាររបស់អង្គការទស្សនៈពិភពលោក ទើបឪពុកម្តាយរបស់គាត់បានស្គាល់ថាអង្គការទស្សនៈពិភពលោកជាអង្គការគ្រីស្ទាន ។ តាមរយៈការនាំចូលព្រះវិហាររាល់អាទិត្យ របស់អ្នកស្រីម៉ូលី ពេលនោះ សុគន្ធ និង សុធារីបានក្លាយជាអ្នកជឿព្រះយេស៊ូដែរ និងរៀនធ្វើការជាមួយកុមារនៅក្នុងព្រះវិហារ ។ ឪពុកម្តាយក៏ចាប់ផ្តើមជូនពួកគេទៅមកពីផ្ទះទៅព្រះវិហារបន្ទាប់ពីគេបញ្ចប់ការងារនៅព្រះវិហារ ។ សុគន្ធជាប្អូនស្រីរបស់អ្នកស្រីមូលីបានក្លាយជាគ្រូបង្រៀន នៅឆ្នាំ ១៩៧០ ហើយក្រោយមក សុគន្ធបានធ្វើការជាមួយវិទ្យុអេហ្វ អ៊ី ប៊ី ស៊ី នៅក្នុងឆ្នាំ១៩៩០ ។ ឥឡូវនេះ សុគន្ធ ធ្វើការជាមួយអង្គការទស្សនៈពិភពលោកកម្ពុជាក្នុងឋានៈជាបុគ្គលិកផ្នែកអភិវឌ្ឍន៍សហគមន៍ និងបានធ្វើទីបន្ទាល់ពីគ្រីស្តបរិស័ទបាន យ៉ាងល្អប្រសើរ ។

នៅចុងឆ្នាំ ១៩៧៤ អាន់ទីប៉ូ បានផ្សាយដំណឹងពីព្រះគ្រីស្តដល់ បងស្រីពីរនាក់ទៀតរបស់មូលី ឈ្មោះ យស់ ឯមស៊ីថាន និង យស់ សាំងកានី ពេលនោះពួកចាប់ផ្តើមបង្ហាញពីផលផ្លែដែលគេបានឮដំណឹងល្អ។ នៅពេល

ដែលពួកខ្មែរក្រហមបានផ្តើមបាញ់ផ្លោងចូលមកក្នុងទីក្រុងបងស្រីទាំងពីរក៏សម្រេចចិត្តថ្វាយជីវិតរបស់គេទៅព្រះគ្រីស្ទ ។

ទ្រាវ សារី ដែលជានាយក និង ជាអ្នកចាត់ចែងការនៅក្នុងមជ្ឈមណ្ឌលយុវជនបានយល់ឃើញថាទោះបីជាគាត់ខំផ្សាយដំណឹងល្អ និង បង្ហាត់គេឲ្យទៅជា សិស្សយ៉ាងណាក៏ដោយ បែរជាក្រុមជំនុំដទៃទៅវិញទេ ដែលបានប្រើយុវជនទាំងអស់នោះហើយគេមិនដែលអរគុណចំពោះការដែលគាត់ខំបង្ហាត់បង្រៀនគេឡើយ ។ លើសពីនោះទៅទៀតនោះក្រុមជំនុំជាច្រើន ដូចជាក្រុមជំនុំ បេថានី និង ក្រុមជំនុំបេថ្លេហិមមានក្រុមជំនុំ កើនឡើងច្រើនកាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃដោយព្រោះមានជនភៀសខ្លួនកើនឡើងហូរចូលក្រុងភ្នំពេញជារៀងរាល់ថ្ងៃ ។ ដូច្នេះលោក ទ្រាវសារី បានសម្រេចចិត្តរៀបចំឲ្យមានការថ្វាយបង្គំព្រះនៅឯមជ្ឈមណ្ឌលយុវជន នៅថ្ងៃអាទិត្យ ។ មូលី្ល និង អាន់ទីប៉ូបានស្នាក់នៅក្រុមជំនុំបេថានី ហើយជួយក្រុមជំនុំតូចៗដូចជាព្រះវិហារទូករបស់លោក ណូអេ ជាផ្ទះទូកដែលគៀងជាប់នៅច្រាំងខាងលិចនៃទន្លេមេគង្គ ។ ទូកលោក ណូអេ ជាកម្មសិទ្ធិរបស់អ្នកជឿថ្មីម្នាក់ចេញពីក្រុមជំនុំ បេថ្លេហិម ហើយសិស្សនៃមហាវិទ្យាល័យព្រះគម្ពីរតាខ្មៅដែលបានអធិប្បាយ និង បានដឹកនាំកម្មវិធីនៅទីនោះ ។

ខ្មែរក្រហមកាន់តែខិតមកជិត និង មានការបាញ់ប្រហារគ្នានៅតាមតំបន់ជាយក្រុង ។ អៀង ដែលភូមិរបស់គាត់បានទទួលរងនូវការបាញ់ប្រហារគ្នារវាងទាហានលន់ណុល[២] និង ទាហានខ្មែរក្រហម អៀង បានរត់ភៀសខ្លួនចូលទៅក្នុងទីក្រុងភ្នំពេញ ហើយគ្រួសារគាត់បានទិញផ្ទះមួយនៅជិតផ្សារអូឡាំពិច។ អៀង និង មូលី្ល ធ្វើការគ្រប់យ៉ាងទាំងអស់ជាមួយគ្នាបន្ទាប់ពីនោះមក ។ អាន់ទីប៉ូ ស៊ីថាន និង សង្វានី លក់បន្លែនៅផ្សារដើមថ្កូវម្តុំទំនប់ទឹក ។ ពេលមួយ

---

*[២] កងទ័ពជាតិកម្ពុជា ដែលជាទាហានរដ្ឋាភិបាលសាធារណរដ្ឋ លន់ ណុល*

នៅក្នុងឆ្នាំ ១៩៧៤ មូល្លី បានចូលរួមក្នុងពិធីបុណ្យជ្រមុជទឹកដ៏ធំមួយដែលធ្វើឡើងដោយមហាវិទ្យាល័យព្រះគម្ពីរតាខ្មៅ ។ អ្នកស្រីបានចងចាំពីសេចក្ដីក្លាហានអធិស្ឋាន សំរាប់សេចក្ដីសង្គ្រោះដល់ឪពុកម្ដាយរបស់អ្នកស្រី ដោយគ្រូគង្វាលយុវជនម្នាក់ឈ្មោះលោក ង៉ែត សាម៉ន ហៅ ស៊ីថា។

ពេលដែលបុណ្យណូអែលចូលមកដល់ពួកគេបានអបអរសាទរថ្ងៃបុណ្យណូអែលនោះជាមួយ រូស អេឡែន និង អាលីស នៅឯផ្ទះរបស់ពួកគេជាមួយក្រុមជំនុំដទៃទៀតជុំវិញភ្នំពេញ ។ បេសកជនបរទេសទាំងអស់នៅផ្ទះលេខ៧២ កំពុងរៀបចំវ៉ាលីសរបស់ពួកគេដើម្បីចាកចេញពីព្រោះនេះជាឱកាសរបស់ពួកគេហើយមុនពេលដែលខ្មែរក្រហមចូលដល់ទីក្រុង ។ បេសកជនដែលជាមិត្តរបស់ម៉ូលីប្រាប់គាត់ថាកុំឲ្យខ្មែរក្រហមចាប់បានសៀវភៅអង់គ្លេសនិង ព្រះគម្ពីរខ្មែរនៅជាមួយគាត់ឲ្យសោះ ។

នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានចូលក្នុងទីក្រុងភ្នំពេញពួកគេចាប់ផ្ដើមសម្លាប់ទាហានលន់ណុលនិងអ្នកដទៃទៀត ដែលធ្វើការជាមួយរដ្ឋាភិបាល ។ មានទាហានជាច្រើនបានយកឯកសណ្ឋានរបស់ខ្លួនទៅកប់ ហើយបានចូលរួមការជម្លៀសខ្លួនយ៉ាងធំចេញពីទីក្រុង ។ អ្នកដែលរស់នៅទីក្រុងភ្នំពេញទាំងអស់ដែលជម្លៀសទៅតាមបណ្ដាខេត្តផ្សេងៗត្រូវបានហៅថា " ប្រជាជនថ្មី " ។ មានអ្នកទីក្រុង ជាច្រើនបានទទួលនូវការអត់ឃ្លាន និង ធ្វើការជាទម្ងន់រហូតដល់ស្លាប់ ។ អ្នកខ្លះក៏ត្រូវគេចាប់ខ្លួនយកទៅបាត់ហើយបាត់ខ្លួនជារៀងរហូត ។

ដំណើរភៀសខ្លួនដ៏ធំនេះដែលមានមនុស្សកកកុញជាង ២ លាន នាក់ មូល្លី និង គ្រួសាររបស់គាត់ធ្វើដំណើរឆ្ពោះទៅភូមិកំណើតរបស់ពួកគេនៅខេត្តព្រៃវែង ។ ពួកគេឆ្លងទន្លេមេគង្គតាមអ្នកលឿងហើយទៅដល់ភូមិមួយឈ្មោះកំពង់ត្របែក ។ នៅក្នុងភូមិនោះ ពួកគេបានសង់ខ្ទមមួយដែលធ្វើពីឬស្សី និង ស្លឹកត្នោត ។ បន្ទាប់ពីបានមកដល់ខេត្តព្រៃវែងសមាជិកភាគច្រើននៅក្នុង

គ្រួសារកើតជំងឺគ្រុនចាញ់ ។ ក្នុងអំឡុងពេលដែលមានជំងឺយ៉ាងដូច្នេះ ឪពុកម្ដាយ ម្ងលី ក៏សូមឲ្យនាងនាំពួកគាត់ឲ្យស្គាល់ព្រះគ្រីស្ទដែរ ។ ម្ងលី និងម្ដាយរបស់នាងមានជំងឺធ្ងន់ជាងគេ ហើយត្រូវបានគេនាំទៅអង្គការសុខភាពរបស់ខ្មែរក្រហម ។ មណ្ឌលសុខភាពនោះគ្មានថ្នាំពេទ្យទេ ហើយអ្នកជំងឺខ្លះត្រូវបានយកចេញទៅសម្លាប់ចោល ។

បន្ទាប់ពីប៉ុន្មានខែក្រោយមកម៉ូលីបានជាពីជំងឺ ប៉ុន្តែម្ដាយរបស់គាត់កាន់តែយ៉ាប់យឺនឡើង ។ អ្នកដែលនៅមណ្ឌលសុខភាពទាំងអស់ចង់បញ្ជូនម្ដាយរបស់គាត់ទៅស្លាប់នៅឯផ្ទះនៅពេលដែលគាត់សន្លប់បាត់ស្មារតីរហូតដល់ ៣ ថ្ងៃ ។ នៅក្នុងខណៈដែលគាត់សន្លប់ ៣ ថ្ងៃគាត់បានឃើញខ្មោចដែលមានសក់យ៉ាងច្រើនកំពុងដេញគាត់ គាត់មានការអស់កំលាំងយ៉ាងខ្លាំងក្នុងការរត់គេចខ្មោចទាំងនោះ ។ ស្រាប់តែមានស្រ្តី ២ នាក់មកតាមគាត់ម្នាក់បានលើកដៃគាត់ឡើងហើយជួយគាត់ ។ ស្រ្តីនោះបានប្រាប់គាត់ឲ្យខំប្រឹងទៀត ។ នៅពីចំងាយមានព្រះវិហារសមួយ ។ ស្រីទាំងពីរនាក់នាំគាត់ឆ្លងកាត់ព្រះវិហារសនោះហើយប្រាប់គាត់ថានោះគឺជាព្រះវិហាររបស់សាសនា ។ គាត់បានឃើញព្រះវិហារមួយទៀតមួយនេះមានឈាមក្រហម ហើយនៅយ៉ាងឆ្ងាយឯនាយសមុទ្រយ៉ាងធំ ។ ខ្មោចចេះតែបន្តដេញចាប់គាត់ ។ ពួកវាហែលទឹកប៉ុន្តែគាត់អាចដើរលើទឹកបាន ។ ក្នុងខណៈពេលដែលគាត់បានមកដល់ច្រាំងហើយ បោះជំហានគាត់ទៅព្រះវិហារហើយខ្មោចនោះបានចាប់គាត់បាន ។ នៅក្នុងពេលនោះស្រាប់តែគាត់ស្រែកឡើងថា" ព្រះយេស៊ូជួយខ្ញុំផង" ។ គាត់ក៏ឃើញព្រះយេស៊ូនេះគឺជាថ្ងៃជំនុំជំរះ ។ នៅពេលដែលឮយ៉ាងដូច្នេះខ្មោចក៏រត់គេចបាត់ទៅ ។ ម្ដាយរបស់ម្ងលី ក្រោយពីពេលនោះមកចាប់ផ្ដើមកំរើកមេជើងជាសញ្ញាឲ្យដឹងថាគាត់នៅមានជីវិតនៅឡើយ ។

មិនយូរប៉ុន្មានបន្ទាប់ពីគាត់វិលត្រឡប់មកពីមណ្ឌលសុខភាពរួចមកគាត់ក៏មានសុខភាពល្អ ។ ក្រុមគ្រួសារចាប់ផ្ដើមអានព្រះគម្ពីរដោយសំងាត់

ប៉ុន្តែក្រោយមកហេតុការណ៍កាន់តែធ្ងន់ធ្ងរទៅ ហើយពួកគេក៏កប់ព្រះគម្ពីរ ដោយព្រោះខ្លាចស្លាប់ដោយខ្មែរក្រហម ។ ទោះបីយ៉ាងដូច្នេះក៏ដោយក៏ជំនឿរបស់ម្តាយមូលី នៅតែលូតលាស់ល្អ ។ ប៉ុន្តែការល្បងលក៏មកដល់ គឺថាសុធារី ដែលជាកូនពៅនៅក្នុងគ្រួសាររងទុក្ខដោយគ្មានថ្នាំព្យាបាលដោយជំងឺគ្រុនឈាម អស់រយៈពេល ៧ ថ្ងៃ ហើយក៏បាត់បង់ជីវិតទៅ ។ មូលី ត្រូវបង្ខំដោយស្ទូងស្រូវ និង លើកភ្លឺស្រែដែលទទួលបានតែបបររាវតែមួយផ្តិលដែលមានអង្ករតែបន្តិចនៅបាតចាន ។ នៅពេលដែលឃើញសត្វឆ្កែរត់ធ្វើឲ្យនាងស្រក់ទឹកមាត់នឹកឃើញពីសាច់ឆ្កែអាំងដែលគួរឲ្យឆ្ងាញ់ ។ ពីព្រោះតែខ្វះអាហារ ហើយធ្វើការយ៉ាងធ្ងន់ធ្ងរ មូលី ក៏ធ្លាក់ខ្លួនឈឺ ។ គាត់មានជំងឺរាករហូត ហើយក៏មានការខ្សោះជាតិទឹកយ៉ាងឆាប់រហ័ស ហើយទទួលនូវការរងឈឺចាប់ដោយពុំបានទទួលអាហារគ្រប់គ្រាន់ ។ អង្គការបានបញ្ជូនគាត់ទៅសំរាកនៅឯមណ្ឌលសុខភាព ។

ខ្មែរក្រហមប្រុងប្រៀបធ្វើពិធីរៀបការយ៉ាងធំមួយនៅភូមិរបស់មូលី។ ម្តាយរបស់នាងទាមទារឲ្យមូលីវិលពីមន្ទីរពេទ្យ ហើយមកចូលរួមពិធីនេះដែរ ដោយគាត់គិតថាប្រសិនបើមូលី រៀបការជាមួយអ្នកភូមិនេះនោះម៉ូលីនឹងបានរស់នៅជិតគាត់ ។ ពីដំបូងមូលី អត់សប្បាយនឹងគំនិតនេះទេ ប៉ុន្តែក្រោយមកក៏យល់ព្រមទៅនឹងសេចក្តីប្រាថ្នារបស់ម្តាយគាត់ ហើយក៏រៀបការជាមួយពុត សាផារុង នៅក្នុងក្រុមរៀបការទាំងអស់ក្នុង ឆ្នាំ ១៩៧៨ ។ បងស្រីរបស់គាត់ យស់ អែមស៊ីថាន បានរៀបការក្នុងថ្ងៃតែមួយនោះដែរ ។

១០ថ្ងៃក្រោយមក បានបង្ខំគូរៀបការទាំងអស់ឲ្យប្តូរទីតាំងទៅខេត្តពោធិសាត់ នៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ។ ម្តាយឪពុក និង ប្អូនស្រី របស់គាត់ក៏សំរេចចិត្តទៅទីនោះជាមួយគ្នាដែរ ហើយក៏ធ្វើដំណើរទៅអ្នកលឿងត្រើយខាងលិច ។ ចាប់ពីកន្លែងនោះពួកគេបានជិះរថយន្តឆ្ពោះទៅខាងជើងទីក្រុងភ្នំពេញដែលគ្មានមនុស្សរស់នៅ ។ ពីភ្នំពេញពួកគេជិះរថភ្លើងឆ្ពោះទៅខាងជើងទៀតតំរង់ទៅពោធិសាត់ ។ ក្នុងកំលុងពេលដ៏ពិបាកនៅក្រោមខ្មែរក្រហមប្តីរបស់

គាត់បានចែកចាយអាហារអ្វីដែលខ្លួនមានដល់គាត់ ហើយជួយលើរបស់របរគាត់ នៅពេលដែលពួកខ្មែរក្រហមបង្ខំឲ្យចាកចេញ ។ គាត់មានដំបៅក្លាយលើដៃរបស់គាត់យ៉ាងធ្ងន់ធ្ងរ ហើយគាត់ដឹងយ៉ាងច្បាស់ថាដោយសារតែប្ដីរបស់គាត់ជួយលី សែងឥវ៉ាន់ ទើបគាត់អាចរស់នៅបាន ហើយអត់ទ្រាំក្នុងការធ្វើដំណើរយ៉ាងលំបាកនេះទៅមុខរួច ។

អាន់ទីប៉ូបាត់ដំណឹងសូន្យតាំងពីបែកភ្នំពេញនៅពេលដែលគាត់ទៅលេងសង្សាររបស់គាត់ចំពេលដែលខ្មែរក្រហមវាយចូលទីក្រុង។ គាត់ត្រូវគេបញ្ជូនទៅបាត់ដំបងគឺជាទីក្រុងធំ ទីពីររបស់ប្រទេសកម្ពុជានៅ ប៉ែកពាយ័ព្យនៅជិតនឹងព្រំដែនថៃ ។ ម៉ូលីនៅចាំបានថាពេលដែល អាន់ទីប៉ូ បាននិយាយប្រាប់ថាពួកខ្មែរក្រហមចងគាត់ដើម្បីយកទៅសម្លាប់បីដង ប៉ុន្តែ ៣ ដង នោះឡានដែលដឹកអ្នកទោសយកទៅសម្លាប់នោះពេញទាំងអស់ដែល សូម្បីតែម្នាក់ទៀតក៏មិនអាចញាត់ចូលឡាននោះបាន ។ បន្ទាប់ពីលើកទី៣ អាន់ទីប៉ូ បានរត់គេចទៅប្រទេសថៃហើយបានចូលរួមក្នុងចលនាតស៊ូដែលដឹកនាំដោយអតីតនាយករដ្ឋមន្ត្រី កាលពីក្នុងអំឡុង ឆ្នាំ ១៩៦០ គឺ លោកតា សឺនសាន KPNLF ( ខ្មែរឥស្សរៈ ) ក្នុងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដែលប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម ។ គាត់ធ្វើការជាគណនេយ្យករសំរាប់ KPNLF រហូតដល់គេចោទគាត់ថា គាត់លួចលុយ ហើយគេបញ្ជូនគាត់ទៅសមរភូមិមុខ ហើយគាត់បានត្រូវបាញ់ត្រូវរបួសយ៉ាងធ្ងន់ធ្ងរ ។ គាត់បានទៅសំរាកព្យាបាល នៅមន្ទីរពេទ្យក្នុងប្រទេសថៃ រួចក៏បានជាសះពីមុខរបួស ហើយរស់នៅប្រទេសថៃជាមួយគ្រួសារជនជាតិថៃ រហូតដល់គាត់បានជាសះស្បើយមែនទែន ។

ក្នុងឆ្នាំ ១៩៧៨ គឺជាឆ្នាំដែលមានការពិបាកខ្លាំងណាស់សំរាប់ប្រទេសកម្ពុជាព្រោះមានការខ្វះខាតអាហារ ពីព្រោះខ្មែរក្រហមដឹកស្រូវអង្ករចេញយ៉ាងច្រើនទៅប្រទេសចិន និងមួយចំនួនទៀតគេបានយកទៅលាក់ទុក នៅក្នុងរូងភ្នំ ។ ទឹកជំនន់បានបំផ្លាញផលស្រូវឆ្នាំនោះយ៉ាងធ្ងន់ធ្ងរដែលធ្វើឲ្យមាន

អំណាត់ប៉ះទង្គិចយ៉ាងខ្លាំងដល់ប្រជាជនក្នុងឆ្នាំនោះ ព្រោះប្រជាជនមានតែស្រូវអង្ករ នោះហើយដែលត្រូវពឹងអាង ។

ក្នុងថ្ងៃបុណ្យណូអែលឆ្នាំ ១៩៧៨ កំលាំងទ័ពវៀតណាមបានចូលក្នុងប្រទេសកម្ពុជា បន្ទាប់ពីខ្មែរក្រហមបានកាប់សម្លាប់ជនជាតិវៀតណាមដែលរស់នៅតាមព្រំដែនកម្ពុជាវៀតណាម ជាពិសេសនៅកម្ពុជាក្រោម និងតាមដីសណ្តនៃទន្លេមេគង្គ ។ នៅថ្ងៃទី ៧ មករា ១៩៧៩ កងទ័ពវៀតណាមបានទទួលជ័យជំនះ ហើយបានចូលមកគ្រប់គ្រងទីក្រុងភ្នំពេញទាំងស្រុង ។ ចាប់ពីពេលនោះមកគេបានបណ្តេញអ្នកដឹកនាំខ្មែរក្រហមឲ្យទៅលាក់ខ្លួននៅតាមដងភ្នំប៉ែកពាយ័ព្យតាមព្រំដែនថៃកន្លែងនោះហើយ ដែលពួកគេរស់នៅយ៉ាងសុខសាន្តក្រោមការការពាររបស់ពួកទាហានថៃនៅតាមព្រំដែន ។

ទាហានវៀតណាមបានអនុញ្ញាតឲ្យមូល្លី និង គ្រួសាររបស់គាត់ធ្វើដំណើរចាកចេញពីខេត្តពោធិសាត់ ប៉ុន្តែមិនអនុញ្ញាតឲ្យវិលត្រឡប់ចូលទៅភ្នំពេញវិញឡើយ ។ ពួកគេក៏ធ្វើដំណើរទៅព្រៃវែងវិញ ។ សំណាងល្អដែលពួកគេអាចវិលត្រឡប់ទៅឯកន្លែងដែលគេធ្លាប់រស់នៅក្នុងឆ្នាំ១៩៦០ គឺ មិនបានទៅកន្លែងដែលគេរស់នៅកាលពីសម័យ ប៉ុល ពត នោះឡើយ ។ ពេលនោះជារដូវចំរូត ប៉ុន្តែពួកខ្មែរក្រហមដែលរងរបួសហើយបានរត់គេចពីការដេញតាមរបស់ពួកទាហានវៀតណាមនោះបានដុះបំផ្លាញស្រូវនៅវាលស្រែដាក់ថ្នាំបំពុលក្នុងអណ្តូងទឹកបំផ្លាញផ្លូវថ្នល់ និង ផ្ទះសម្បែងជាច្រើនត្រូវខូចខាត ។ គ្រួសាររបស់មូល្លី មានអាហារតែបន្តិចបន្តួចតែប៉ុណ្ណោះ ហេតុដូច្នេះហើយបានជាត្រូវបង្ខំចិត្តឲ្យសុំអាហារពីអ្នកជិតខាងរបស់ខ្លួន ។ ពួកគេធ្វើការជាច្រើនម៉ោងក្នុងការភ្ជួររាស់ និង ដកស្ទូងស្រូវក្នុងស្រែរបស់អ្នកជិតខាងដើម្បីយកកម្លាំងទៅដូរអាហារ និង ស្រូវដើម្បីឲ្យបានបរិភោគ ។ សំរាប់ពេញមួយឆ្នាំនោះគេមានអាហារបំរុងទុកតែបន្តិចបន្តួចប៉ុណ្ណោះដើម្បីទុកបរិភោគ ។ មានមនុស្ស ៦សែននាក់បានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងឆ្នាំទី១ ដែលវៀតណាមចូលកាន់កាប់ ។

នៅក្រោមកម្មវិធី ក៥ របស់វៀតណាមប្រជាជនកម្ពុជាណាម្នាក់ដែលគេរកឃើញថាមិនគាំទ្ររបបនោះនឹងត្រូវបញ្ជូនទៅកាប់ព្រៃ និង សង់លេណដ្ឋានការពារប្រឆាំងនឹងខ្មែរក្រហមដែលនៅតាមដងភ្នំនៅក្នុងខេត្តបាត់ដំបង [៣]។

រដ្ឋាភិបាលថ្មី គឺសាធារណៈរដ្ឋប្រជាមានិតកម្ពុជាដឹកនាំដោយ លោក ហេង សំរិន ជា ស៊ីម និង ហ៊ុន សែន ( ទាំងអស់មានសម្ព័ន្ធភាពជាមួយវៀតណាម ) បានហៅឪពុករបស់មូលី្ល ឲ្យចូលមកបំរើក្នុងរដ្ឋាភិបាលវិញ ដោយមានឋានៈជាអ្នកកសិកម្ម និង ផ្ដល់ការរៀនសូត្របន្ត ។ នៅចុងឆ្នាំគំរប់មួយឆ្នាំនៃការរស់នៅក្នុងភូមិកំណើតរបស់ខ្លួននៅព្រៃវែង ពួកគេក៏ធ្វើដំណើរត្រឡប់ទៅរស់នៅឯភ្នំពេញវិញ ហើយមូលី្ល ក៏បានធ្វើដំណើរទៅធ្វើការនៅក្រសួងកសិកម្ម ។ ប្ដីរបស់អ្នកស្រីក៏ធ្វើដំណើរទៅធ្វើការនៅទីនោះដែរ ហើយគាត់មានមិត្តភក្ដិជាច្រើនដែលជះឥទ្ធិពលអាក្រក់ទៅលើគាត់ ។ ទីបំផុតក៏ចាប់ផ្ដើមចាយលុយប្រាក់ខែដ៏តិចតួចទៅផឹកស្រា និង លេងល្បែង ។ នៅពេលដែលកូនទី ១ ចាប់ផ្ដើមកើត នៅក្នុងឆ្នាំ ១៩៨១ គាត់មិនបានយកចិត្តទុកដាក់ដល់ការមើលថែមូលី្ល ទេ ឬ ក៏ជួយថែទាំគ្រួសារឡើយ ។ មូលី្ល ព្យាយាមយ៉ាងអស់ពីចិត្តធ្វើយ៉ាងណា ដើម្បីផ្លាស់ប្ដូរអត្តចរិតរបស់ប្ដីគាត់ ប៉ុន្តែអ្នកស្រីធ្វើមិនបានឡើយ ហើយ អ្នកស្រីក៏សំរេចសុំឈប់ធ្វើការងារមកចិញ្ចឹមកូនដោយខ្លួនឯងដោយគ្មានការជួយពីប្ដីគាត់ទេ អ្នកស្រីពឹងផ្អែកទៅលើម្ដាយ និង បងប្អូនស្រីៗរបស់អ្នកស្រីសំរាប់ជួយផ្ដល់អាហារ និងថវិកាផ្សេងៗសំរាប់បង់ការចាយវាយរាល់ថ្ងៃ ។ ពេលមួយក្នុងដើមឆ្នាំ ១៩៨០ ម៉ូលីបានជួបអៀងម្ដងទៀត ។ អៀងកំពុងថ្វាយបង្គំលួចលាក់នៅក្រោមជំនុំតាខ្មៅ ហើយគាត់ក៏អញ្ជើញ ម៉ូលីឲ្យចូលរួមជាមួយគាត់ដែរ ប៉ុន្តែឪពុករបស់មូលី្ល និយាយថា " ទេ ! វាគ្រោះថ្នាក់ណាស់ " ។ មូលី្ល មានការរីករាយពីកិច្ចការខាងឯព្រះវិញ្ញាណ តែបន្តិចបន្តួចតែប៉ុណ្ណោះ

---

[៣] *កម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម*

កាលពីឆ្នាំ១៩៧៥ ។ ប៉ុន្តែក្នុងឆ្នាំ ១៩៨៨ ឪពុក របស់អ្នកស្រីចាប់ផ្តើមមានជំងឺលើសឈាម ដូច្នេះមូល្លី ក៏ទៅរកអៀងដើម្បីនាំគាត់ទៅរកគ្រូគង្វាលរបស់គាត់ឈ្មោះ លោកគ្រូ សៀងអង់ដែលអធិស្ឋានឲ្យឪពុកមូល្លី ហើយលាបប្រេងឲ្យគាត់ ។ បន្ទាប់ពីប៉ុន្មានខែក្រោយមកគាត់ក៏អនិច្ចកម្មទៅ ហើយបានទៅនៅជាមួយព្រះអម្ចាស់ ។

ដោយព្រោះគ្រួសារទាំងមូលចង់បញ្ចុះសពឪពុកគាត់តាមរបៀបគ្រីស្ទបរិស័ទជាជាងធ្វើពិធីបូជាដូចជាអ្នកកាន់សាសនាព្រះពុទ្ធនោះ ដូច្នេះពួកគេក៏បានអញ្ជើញលោកគ្រូ សៀង អង់ ឲ្យមកធ្វើពិធីបុណ្យសព ។ ពេលនោះគឺជាខែកក្កដា ឆ្នាំ ១៩៨៨ ។ ពួកគេមិនចាំបាច់ទៅសុំច្បាប់រដ្ឋអំណាចអ្វីទេហើយក៏ធ្វើបុណ្យសពតែម្តង ។ ការធ្វើពិធីបុណ្យនោះធ្វើឡើងធំដុំមែនទែន ។ មិត្តភក្តិជាច្រើនរបស់ឪពុកគាត់មកពីក្រសួងរដ្ឋាភិបាលបានមកចូលរួមក្នុងពិធីនោះដែរ ដូចជាមិត្តភក្តិរបស់ មូល្លី ស៊ីថាន និង កូនៗរបស់ពួកគេដែរ ។ ក្រុមជំនុំដែលលាក់ខ្លួនបានលេចចេញក្រៅជាលើកដំបូងនៅក្នុងពិធីសពនេះ ។ ពួកគេទាំងអស់គ្នាច្រៀងហើយថ្វាយបង្គំព្រះ ។ មានគ្រីស្ទបរិស័ទ មុនឆ្នាំ ១៩៧៥ ជាច្រើន និង អ្នកខ្លះទៀតទទួលព្រះគ្រីស្ទតាមរយៈការផ្សាយដំណឹងល្អរបស់ស្ទេនមូនីហាម ក៏មកចូលរួមក្នុងពិធីបុណ្យសពនោះដែរ ។ ក្នុងនោះមានលោកគ្រូ អ៊ឹម ជ្រេន លោកគ្រូ មុត ប៊ុនធី កញ្ញា យង់ សេដ្ឋា លោកស្រី ង៉ែត សំបូរ កញ្ញា ស្រី ហៃម និងម្តាយរបស់គាត់ក៏ដូចជាមូល្លី និងក្រុមគ្រួសាររបស់គាត់ ។ មូល្លី និង ម្តាយរបស់គាត់ចងចាំពីក្បួនដង្ហែសពមានក្បួនហែយ៉ាងវែងដែលគាត់ចាំមិនភ្លេចឡើយ ។

ខណៈនោះស្រាប់តែមានបញ្ហាកើតឡើង ដោយមិនគិតជាមុន " តើយើងកប់នៅកន្លែងណា ? " មានគ្រីស្ទបរិស័ទខ្មែរវៀតណាមម្នាក់ ឈ្មោះ លោក ប៉ុល បា បានជួយទាក់ទងព្រះវិហារកាតូលិក ដែលអនុញ្ញាតឲ្យសពឪពុកមូល្លីកប់នៅទីនោះបាន គឺនៅក្នុងទីបញ្ចុះសពកាតូលិកវៀតណាមនៅក្នុងស្រុក

កៀនស្វាយ ដោយគ្រាន់តែឆ្លងស្ទឹងទៅទិសពាយ័ព្យនៃផ្លូវជាតិលេខ ១ ។

តាមរយៈបុណ្យសពនេះ ធ្វើឲ្យមូល្លី ដឹងថាមានអ្នកជឿដែលកំពុងជួបជុំគ្នាដោយសំងាត់នៅជុំវិញក្រុង ។ នៅក្នុងឆ្នាំ ១៩៨៩ បានស្រង់ស្ថិតិថាមានគ្រីស្ទបរិស័ទមិន លើសពី ២០០នាក់ទេដែលថ្វាយបង្គំនៅជុំវិញទីក្រុងភ្នំពេញ ។

មូល្លី បាននិយាយថា " មានថ្ងៃមួយមិនយូរប៉ុន្មានក្រោយពិធីបុណ្យជ្រមុជទឹកជាសាធារណៈនៅស្ទឹងកន្ទួតខាងលិចភ្នំពេញ ( ដែលគេបានធ្វើដោយលួចលាក់នោះ ដែលមានអ្នកជឿប្រហែលជា ៥០ នាក់ ) ខ្ញុំបានឃើញបងស្រីខ្ញុំ ស៊ីថាន បានកាន់ក្រដាសនៅនឹងដៃគាត់ ។ គាត់បានសូមឲ្យគ្រីស្ទបរិស័ទដទៃទៀតចុះហត្ថលេខា ។ នាងមានហត្ថលេខា ១០ សំរាប់សុំការអនុញ្ញាតអ្វីមួយ ។ ពេលនោះបងស្រីគាត់ ធ្វើការនៅក្រសួង អប់រំជាតិ ហើយគាត់មានការគោរពរាប់អានពីអ្នករួមការងារជាមួយគ្នា ។ គាត់បានដាក់ពាក្យសុំទៅមនុស្សសំខាន់ម្នាក់នៅក្នុងជួររដ្ឋាភិបាលដែលបញ្ជូនតទៅទៀតតាមលំដាប់ទីបំផុតពាក្យសុំនោះបានទៅដល់ការិយាល័យក្រសួងធម្មការ និងកិច្ចការសាសនា ។ សំណាងល្អ ស៊ីថាន មានមិត្តដ៏យូរអង្វែងម្នាក់ដែលត្រូវជាប្រពន្ធរបស់មន្ត្រីម្នាក់នៅក្នុងក្រសួងនោះ ហើយគាត់ក៏ជួយសម្រួលឲ្យមានឱកាសក្នុងការចូលទៅជួបប្តីរបស់គាត់ ។ មូល្លី និង បងស្រីរបស់គាត់បានទៅជួបបុរសដែលជារដ្ឋមន្ត្រី នោះហើយនិយាយស្នាបស្នង់ចិត្តគាត់ថា ៖ " នៅក្នុងរបបនេះយើងគ្មានសិទ្ធិក្នុងការថ្វាយបង្គំតាមប្រពៃណីរបស់យើងឡើយ យើងគ្មានកន្លែងបញ្ចុះសពគ្នាយើង យើងគ្មានសិទ្ធិអ្វីទាំងអស់ តើវាជាការមិនត្រឹមត្រូវមែនដែរឬអត់? តើលោកអាចធ្វើអ្វីម្យ៉ាងសំរាប់យើងបានឬទេ?"

បងប្អូនស្រីត្រកូលយស់ទាំងបី មូល្លី ស៊ីថាន និង សុគន្ធ ជិះកង់ ទៅផ្ទះរដ្ឋមន្ត្រីនោះជារៀងរាល់ថ្ងៃរសៀលអស់រយៈពេលជាង៣ខែ ។ គាត់ចង់រៀនថែមទៀតអំពីជំនឿលើព្រះគ្រីស្ទដើម្បីឲ្យគាត់អាចលើកយកករណីនេះផ្តល់ជាដំណឹងដល់រដ្ឋាភិបាល ។ ជារៀងរាល់ថ្ងៃរសៀលពួកគេច្រៀងទំនុកតំកើងថ្វាយ

បង្កំព្រះបង្រៀនព្រះគម្ពីរ ហើយស្តាប់ចំរៀងថ្វាយបង្គំតាមកាសែត ។ មន្ត្រីនោះថែមទាំងបានខ្ចីកាសែតចំរៀងស្តាប់តាមឡានរបស់គាត់ទៅធ្វើការនឹងត្រលប់ពីធ្វើការមកវិញ ។ គាត់បានសួរសំណួរជាច្រើនដែលពួកគេបានឆ្លើយ ។

ក្នុងពេលនោះមូលី បានយល់សប្តិថាគាត់និងគ្រួសារគាត់កំពុងរត់ជុំវិញស្តាតអូឡាំពិកស្រែកយ៉ាងរីករាយទៅគ្រប់គ្នាដែលព្ទនៅពីចំងាយថា៖ " ជយោព្រះយេស៊ូ ! ព្រះយេស៊ូ ! " គាត់មានអារម្មណ៍ថាព្រះមានបន្ទូលមកគាត់ថា ៖ ពួកគេនឹងបានត្រូវផ្តល់ជ័យជំនះដែលនឹងបំបាត់អំណាចដ៏ខ្លាំងរបស់សាតាំងនៅលើទឹកដីដ៏ជាទីស្រឡាញ់របស់ពួកគេនេះ ។

ក្នុងខណៈនោះបុណ្យរបស់ឪពុកមូលី បានជំរុញឲ្យអ្នកដឹកនាំគ្រីស្តបរិស័ទក្នុងស្រុកបង្កើតគណៈកម្មាធិការបណ្តោះអាសន្នមួយដែលមានសមាជិក១០នាក់ (បួននាក់ជានារី ) ដែលដឹកនាំដោយគ្រូគង្វាលស៊ាង[៤] ។ បងស្រីរបស់មូលី យស់ អែមស៊ីថានជាសមាជិកនៃក្រុមប្រឹក្សានោះ ។ ពេលនោះជាខែ មិថុនា ឆ្នាំ ១៩៨៩ ហើយគ្រីស្តបរិស័ទកំពុងរង់ចាំការផ្លាស់ប្តូរនៅក្នុងរដ្ឋធម្មនុញ្ញដែលផ្តល់នូវការអត់អោនយោគយល់ដល់គ្រីស្តបរិស័ទ ។ នៅក្នុងខែមិថុនា នោះ ដែលប្រឹក្សារបស់រដ្ឋមន្ត្រីអនុញ្ញាតឲ្យគ្រីស្តបរិស័ទមានសេរីភាពក្នុងការថ្វាយបង្គំដោយជំនឿ ប៉ុន្តែមិនអនុញ្ញាតឲ្យផ្សាយដំណឹងល្អទេ ។

ក្នុងខណៈពេលដែល យស់ ស៊ីថាន ម៉ូលី និង សុគន្ធ និង អ្នកដទៃទៀតកំពុងនៅតែបន្តជួបជាមួយមន្ត្រីរូបនោះនៅឡើយក្រុមជំនុំកម្ពុជាបានត្រូវគេអញ្ជើញឲ្យទៅចូលរួមសន្និសីទពិភពលោកក្រុងឡូសាន II នៅ ប្រទេសហ្វីលីពីន ។ ពួកគេមិនអាចទៅចូលរួមបាន ប៉ុន្តែបានបញ្ជូនរបាយការណ៍ពីហេតុការណ៍ដែលកំពុងជួបប្រទះ ។ នេះគឺជាការជូនដំណឹងមួយដល់អស់អ្នក

---

[៤]Don Cormack, *Killing Fields Living Fields: An Unfinished Portrait of the Cambodian Church—the Church that Would Not Die* (Crowborough, East Sussex: OMF, 1997), 391.

ដែលចូលរួមសន្និសីទអធិស្ឋានឲ្យប្រទេសកម្ពុជាមានសេរីភាពជាផ្លូវការសំរាប់សិទ្ធិសាសនា ។

នៅក្នុងថ្ងៃចុងក្រោយ បងប្អូនទាំងបីជួបមន្ត្រីរូបនោះ លោកសួរថា តើពួកគ្រីស្ទបរិស័ទមានធ្វើនយោបាយឬអត់ ? មូល្លី ពន្យល់ចេញពីគម្ពីររ៉ូម ជំពូក ១៣ ថាព្រះរើសតាំងអ្នកដឹកនាំប្រទេស ហើយគ្រីស្ទបរិស័ទត្រូវចុះចូល និង អធិស្ឋានសំរាប់អស់លោកទាំងនោះ ។ ពួកគាត់ប្រាប់បញ្ជាក់ថា គ្រីស្ទបរិស័ទ នៅក្នុងប្រទេសកម្ពុជាចង់បានតែសេរីភាពក្នុងការថ្វាយបង្គំមិនចង់រំខាន នៅក្នុងប្រទេសដែលកំពុងតែមិនមានស្ថានភាពនឹងនរនេះទេ ។ ថ្ងៃបន្ទាប់មក លោកបានហៅពួកគាត់ត្រឡប់ទៅម្តងទៀតប្រហែលជាមានអ្វីប្លែកហើយ ដោយព្រោះអ្នកដែលនៅថ្នាក់លើគាត់បាននិយាយអ្វីម្យ៉ាង ហើយមើលទៅ ។ លោកបានសូមពួកគេឲ្យពន្យល់លោកម្តងទៀតឲ្យបានច្បាស់អំពីផ្នែកខាងធ្វើនយោបាយ ។ មូល្លី បានពន្យល់ម្តងទៀតថា គ្រីស្ទបរិស័ទនឹងគ្មានបំណងបង្កបញ្ហាដល់រដ្ឋាភិបាលឡើយ ។ នៅថ្ងៃអាទិត្យបន្ទាប់នោះគឺ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៩០ ក្រោយមក១០ខែ បន្ទាប់ពីសន្និសីទឡូសាន ក្នុងកំឡុងពេលថ្វាយបង្គំនៅផ្ទះរបស់ មូល្លី រដ្ឋាភិបាលកម្ពុជាបានប្រកាសជាផ្លូវការអំពីការទទួលស្គាល់ក្រុមជំនុំគ្រីស្ទបរិស័ទ ។ មួយសប្តាហ៍ក្រោយមកមានវត្តមានតំណាងគ្រីស្ទបរិស័ទ ១៥០០ នាក់បានបង្ហាញមុខចំពោះរដ្ឋាភិបាលក្នុងនោះមានរួមទាំង កាតូលិក និង ប្រូតេស្តង់ទាំងជនជាតិខ្មែរ និង វៀតណាម បានធ្វើពិធីបុណ្យ មួយអបអរសាទរសេរីភាពថ្មីជាមួយគ្នានៅក្នុងរោងប្រជុំដ៏ធំជាងគេមួយ នៅក្នុងទីក្រុងភ្នំពេញ ។

រដ្ឋាភិបាលនៅតែបន្តប្រយ័ត្នចំពោះគ្រីស្ទបរិស័ទ មូល្លី និងស៊ីថាន គឺជាមនុស្សក្នុងចំណោមមនុស្សដទៃទៀតដែលមានគេស៊ើបអង្កេត និង តាមដាន ។ ដោយព្រោះស៊ីថាន គឺជាអ្នកដំបូងគេដែលធ្វើចលនាក្នុងការសុំឲ្យមាន សេរីភាពសំរាប់គ្រីស្ទបរិស័ទ រដ្ឋាភិបាលឲ្យគាត់រក្សាភាពប្រុងប្រយ័ត្នយ៉ាងខ្លាំង

ចំពោះការណាមួយក៏ដោយដើម្បីបញ្ជាក់ថាពួកជំនុំមិនធ្វើខុសចំពោះសេរីភាពដែលទើបតែទទួលបាន ។ ការក្តាប់ឲ្យណែនពិតជាមិនអាចទៅរួចបន្ទាប់ពីគ្រីស្ទបរិស័ទចាប់ផ្តើមរីកចំរើនយ៉ាងលឿន ហើយបេសកជន និង គ្រប់និកាយបានមកពីប្រទេសផ្សេងៗបានចូលមកប្រទេសកម្ពុជា ។ មានអ្នកផ្សាយដំណឹងល្អម្នាក់មកពីរដ្ឋតិចសាស់ ឈ្មោះ ម៉ៃ អ៊ីវែន ដែលធ្វើឲ្យមានកំហុសឆ្គងសឹងតែនឹងបាត់សេរីភាពម្តងទៀត សំរាប់គ្រីស្ទបរិស័ទ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៩៤ នៅក្នុងការផ្សាយដំណឹងល្អជាទ្រង់ទ្រាយ ធំមួយខាងផ្នែកប្រោសជំងឺនៅស្តាតអូឡាំពិច ។ មានបេសកជននៅប្រទេសកម្ពុជាជាច្រើនបានផ្តល់គំនិតដល់គាត់មិនឲ្យគាត់ចូលមកទេ ប៉ុន្តែគាត់នៅតែមកពីព្រោះគាត់គិតថាព្រះជាម្ចាស់បានមានបន្ទូលប្រាប់គាត់ឲ្យមក ។ ការផ្សាយដំណឹងល្អនោះ គឺទទួលរងនូវការបរាជ័យដែលមិនបានធ្វើរហូតដល់ចប់តាមការគ្រោងទុក ។ ការផ្សព្វផ្សាយដំណឹងតាមប្រព័ន្ធឃោសនាបានសន្យាថាអស់អ្នកណាដែលចូលរួមនឹងត្រូវប្រោសជា ប៉ុន្តែអ្វីដែលបាននិយាយនោះមិនបានកើតឡើងឡើយ ដែលជាហេតុធ្វើឲ្យក្រុមជំនុំជួបប្រទះនូវការរងទុក្ខវៀតវៀនលើកទី១ បន្ទាប់ពីបានទទួលសេរីភាពរួចមកនោះ ។

យស់ មូលី យស់ អែមស៊ីថាន យស់ សុគន្ធ យ៉ង ស៊ីថា (អៀង) និងគ្រូគង្វាល សៀង អង់ ជាអ្នកដើរតួសំខាន់ក្នុងការសុំឲ្យមានសេរីភាពសំរាប់គ្រីស្ទបរិស័ទ នៅក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ សេរីភាពនោះផ្តល់នូវសេចក្តីអំណរដល់ក្រុមជំនុំអង្គការគ្រីស្ទបរិស័ទអង្គការក្រៅរដ្ឋាភិបាល គ្រីស្ទបរិស័ទបេសកកជន និង ប្រជាជនកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងខែ តុលា ឆ្នាំ ១៩៩១ នៅពេលដែលមូលី ដាក់ពាក្យធ្វើការនៅអង្គការទស្សនៈពិភពលោកកម្ពុជាប្តីរបស់អ្នកស្រីនៅតែលេងល្បែង ។ ពាក្យសុំចូលធ្វើការរបស់ មូលី បានទទួលយល់ព្រម ដូច្នេះធ្វើឲ្យអ្នកស្រី អាចទទួល

នូវបន្ទុកនៃការលេងល្បែងរបស់ប្ដីអ្នកស្រីបានព្រមទាំងជួយផ្គត់ផ្គង់កូនទាំងបីនាក់ ដោយប្រាក់ខែរបស់អ្នកស្រីផ្ទាល់ ។ ពេលខ្លះប្ដីរបស់អ្នកស្រីហាក់បីដូចជា ចង់ផ្លាស់ប្ដូរប៉ុន្តែការផ្លាស់ប្ដូរនេះមានរយៈពេលខ្លីប៉ុណ្ណោះ ។ ពេលខ្លះគាត់មិនមកផ្ទះនៅពេលយប់ហើយពេលខ្លះលេងល្បែងរហូតដល់លក់ ម៉ូតូមួយ ឬពីរដែលមូល្លីបានទិញដោយកំលាំងញើសឈាមរបស់អ្នកស្រី ។ អ្នកស្រីធ្វើការដំបូងនៅអង្គការទស្សនៈពិភពលោកមានតួនាទីជាអ្នកទទួលភ្ញៀវ និង ជាអ្នកកាន់បញ្ជីសារពើភ័ណ្ឌ ប៉ុន្តែ ក្រោយមកជ្រើសរើសឲ្យធ្វើការកន្លែងការិយាល័យទ្រទ្រង់ប្រតិបត្តិការ ហើយបន្ទាប់មកប្ដូរមកកាន់កន្លែងអភិវឌ្ឍន៍ បុគ្គលិក និង ការហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណ និង តួនាទី២ទៀតនៅក្រោមផ្នែកការិយាល័យធនធានមនុស្ស ។ នៅក្រោមការិយាល័យផ្នែកហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណ អ្នកស្រីជួយអង្គការទស្សនៈពិភពលោកកម្ពុជា ផ្នែកខាងរៀបចំច្បាប់ស្ដីពីស្មារបន្ទាល់គ្រប់ជ្រុងជ្រោយរៀបចំ ការប្រកបគ្រួគង្វាលជួយបកប្រែគុណតំលៃរបស់អង្គការទស្សនៈពិភពលោកឲ្យទៅជាភាសាខ្មែរ បង្រៀនបុគ្គលិកខាងផ្នែកព្រះគម្ពីរសំរបសំរួល ការថ្វាយបង្គំថ្ងៃសុក្រ និង វេទិកាព្រះគម្ពីរថ្ងៃអង្គាររៀបចំនិងជួយរៀបចំ Retreat ការណែនាំសំរាប់បុគ្គលិកថ្មី ។ នៅក្នុងខែកុម្ភៈ ១៩៩៨ អ្នកស្រីបានផ្លាស់ប្ដូរទៅខេត្តកំពង់ធំ ។ ខេត្តកំពង់ធំជិះឡាន ៣ ម៉ោងឆ្ពោះទៅខាងជើងក្រុងភ្នំពេញ ។ នៅឯខេត្តកំពង់ធំ មូល្លី ធ្វើការជាអ្នកហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណ និង អ្នកដឹកនាំផ្នែកអភិវឌ្ឍន៍បុគ្គលិកពិតជាមានការងារពីរពេញពេលសំរាប់អ្នកស្រី ។ មួយឆ្នាំក្រោយមកម៉ូលីត្រូវបានជ្រើសរើសឲ្យក្លាយទៅជាប្រធានផ្នែកប្រតិបត្តិការប្រចាំខេត្តកំពង់ធំ ។ នៅក្នុងខែកុម្ភៈឆ្នាំ ២០០២ ដោយព្រោះគិតគិតពីបញ្ហាគ្រួសារ អ្នកស្រីបានវិល ត្រឡប់មកភ្នំពេញមកទទួលការងារកន្លែងមួយដែលមិនសូវជាមមាញឹកគឺ កម្មវិធីអភិវឌ្ឍន៍សាងសង់សមត្ថភាពប្រចាំតំបន់ ។ ប្ដីរបស់អ្នកស្រីទើបតែចាកចោលអ្នកស្រីនៅក្នុងពេលថ្មីៗ ឥឡូវនេះអ្នកស្រីទទួលខុសត្រូវមើលថែកូនបីនាក់ ប្រុសមួយ ស្រីពីរ ។